# ព្រះរាជក្រម

នស/រកម/០៤០៦/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុល រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមកាលកំណត់របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុល
# រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

**មាត្រា ១.-**

អនុម័តយល់ព្រមលើអនុសញ្ញាកុងស៊ុលរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណ-រដ្ឋសង្គមនិយមវៀតណាម ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

ពរល.០៦០៤.១៧១ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ**

**ហត្ថលេខា** លេខ: ១៦៧ ច.ល

**ហោ ណាំហុង**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈៅ ឌី តាន់

5/3

# អនុសញ្ញាកុងស៊ុល

# រវាង

# ព្រះរាជាណាចក្រកម្ពុជា

# និង

# សាធារណរដ្ឋសង្គមនិយមវៀតណាម

ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលអំណិះតទៅហៅថា "ភាគីចុះកិច្ចសន្យា"

ដោយមានបំណងពង្រីកនិងពង្រឹងថែមទៀត នូវចំណងមិត្តភាពនិងទំនាក់ទំនងជាប្រពៃណី រវាងប្រទេសទាំងពីរ

- ដោយប៉ងប្រាថ្នាដោះស្រាយនិងពង្រីកថែមទៀត នូវទំនាក់ទំនងកុងស៊ុល ព្រមទាំងបង្កលក្ខណៈអនុគ្រោះដល់កិច្ចការពារសិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់ របស់ពលរដ្ឋនៃភាគីចុះកិច្ចសន្យាម្ខាង ដែលស្នាក់នៅក្នុងទឹកដីរបស់ភាគីចុះកិច្ចសន្យាម្ខាងទៀត ស្របតាមច្បាប់និងទំលាប់អន្តរជាតិ

បានសំរេចចុះអនុសញ្ញាកុងស៊ុលនេះ ហើយនៅក្នុងទិសដៅនេះ បានព្រមព្រៀងគ្នាដូចតទៅ :

## <u>ជំពូក I</u>

## <u>មាត្រា ១</u>

## និយមន័យ

ក្នុងក្របខ័ណ្ឌអនុសញ្ញានេះ ពាក្យពេចន៍ដែលចែងខាងក្រោម មានន័យដូចតទៅ :

១. *"ប៉ុស្តិ៍កុងស៊ុល"* មានន័យថា ស្ថានអគ្គកុងស៊ុល ស្ថានកុងស៊ុល អនុកុងស៊ុល និង ភ្នាក់ងារកុងស៊ុល

២. *"មណ្ឌលកុងស៊ុល"* មានន័យថា តំបន់ដែលកំណត់សំរាប់ប៉ុស្តិ៍កុងស៊ុលណាមួយ ដើម្បីបំពេញមុខងារកុងស៊ុល

៣. *"ប្រធានប៉ុស្តិ៍កុងស៊ុល"* មានន័យថា ជនដែលត្រូវបានចាត់តាំងឱ្យបំពេញមុខងារ កុងស៊ុល ក្នុងឋានៈនេះ

៤. *"មន្ត្រីកុងស៊ុល"* មានន័យថា រាល់ជនទាំងឡាយណា រួមទាំងប្រធានប៉ុស្តិ៍កុងស៊ុល ដែលត្រូវបានចាត់តាំងឱ្យបំពេញមុខងារកុងស៊ុល ក្នុងឋានៈនេះ

៥. *"និយោជិកកុងស៊ុល"* មានន័យថា រាល់ជនទាំងឡាយណា ដែលត្រូវចាត់ឱ្យបំពេញ ការងារ ក្នុងសេវាបច្ចេកទេស ឬ រដ្ឋបាល របស់ប៉ុស្តិ៍កុងស៊ុល

៦. *"សមាជិកបំរើការងារ"* មានន័យថា រាល់ជនដែលចាត់ឱ្យបំរើការងារផ្ទះ នៅក្នុង ប៉ុស្តិ៍កុងស៊ុល

៧. *"សមាជិកនៃបុគ្គលិកកុងស៊ុល"* មានន័យថា មន្ត្រីកុងស៊ុល និយោជិកកុងស៊ុល និង សមាជិកបុគ្គលិកបំរើការ

៨. *"សមាជិកនៃបុគ្គលិកកុងស៊ុល"* មានន័យថា មន្ត្រីកុងស៊ុល ក្រៅពីប្រធានប៉ុស្តិ៍ កុងស៊ុល និយោជិកកុងស៊ុល និង សមាជិកបុគ្គលិកបំរើការ

៩. *"សមាជិកនៃបុគ្គលិកឯកជន"* មានន័យថា រាល់ជនដែលចាត់ឱ្យបំរើការងារឯកជន ដាច់មុខ ជូនសមាជិកប៉ុស្តិ៍កុងស៊ុល

១០. *"ទីស្ថានកុងស៊ុល"* មានន័យថា អាគារ ឬ ផ្នែកនានានៃអាគារ និង ផ្ទៃដីជាប់ នឹងអាគារនោះ ទោះជាកម្មសិទ្ធិរបស់ជនណាក៏ដោយ ឱ្យតែប្រើប្រាស់ដាច់មុខ ក្នុងផលប្រយោជន៍ របស់ប៉ុស្តិ៍កុងស៊ុល

១១. *"សារស្ថានកុងស៊ុល"* រួមមាន រាល់ក្រដាសស្នាម ឯកសារ លិខិតឆ្លើយឆ្លង សៀវភៅមើល ខ្សែភាពយន្ត ឧបករណ៍បច្ចេកទេសសំរាប់ទទួលនិងតំកល់ពត៌មាន សៀវភៅបញ្ជី របស់ប៉ុស្តិ៍កុងស៊ុល ព្រមទាំងលេខនិងអក្សរសំងាត់ បញ្ជីកែសារនិងរាល់គ្រឿងសង្ហារឹម ប្រើប្រាស់ សំរាប់តំកល់ទុកនិងការពារឯកសារទាំងនោះ

១២. *"លិខិតឆ្លើយឆ្លងជាផ្លូវការ"* មានន័យថា រាល់ការឆ្លើយឆ្លងពាក់ព័ន្ធដល់ប៉ុស្តិ៍ កុងស៊ុល និង ភារកិច្ចរបស់ប៉ុស្តិ៍កុងស៊ុល

១៣. *"សមាជិកគ្រួសាររបស់មន្ត្រីកុងស៊ុល ឬ និយោជិកកុងស៊ុល"* មានន័យថា ភរិយា ឬ ស្វាមី និង កូនអាយុក្រោម១៨ឆ្នាំ របស់មន្ត្រីនិងនិយោជិកកុងស៊ុល ដែលរួមរស់ក្នុង

បន្ទុកគ្រួសាររបស់មន្ត្រី ឬ នយោជិកនោះ

១៤. *"នាវា "* មានន័យថា នាវាស៊ីវិលណាមួយ ដែលដោតទង់ជាតិរបស់រដ្ឋជាក់កុងស៊ុល ស្របតាមច្បាប់របស់រដ្ឋជាក់កុងស៊ុល ដោយមិនរាប់បញ្ចូល នាវាចំបាំង

១៥. *"អាកាសយាន"* មានន័យថា អាកាសយានស៊ីវិល ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងរដ្ឋជាក់កុងស៊ុល ដែលមានសិទ្ធិប្រើប្រាស់សញ្ញាសំគាល់ការចុះបញ្ជីរបស់រដ្ឋនោះ ប៉ុន្តែមិនរាប់បញ្ចូលយន្តហោះយោធាទេ ។

## <u>ជំពូក II</u>

## បទបញ្ញត្តិទូទៅស្តីពីទំនាក់ទំនងកុងស៊ុល

### <u>មាត្រា ២</u>

### ការបង្កើតប៉ុស្តិ៍កុងស៊ុល

១. ប៉ុស្តិ៍កុងស៊ុលអាចបង្កើតនៅក្នុងដែនដីរដ្ឋម្ចាស់ផ្ទះបាន លុះត្រាតែមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ ។

២. ទីតាំង លំដាប់ថ្នាក់ និង មណ្ឌលកុងស៊ុល របស់ប៉ុស្តិ៍កុងស៊ុល ក៏ដូចជាចំនួនសមាជិកនៃបុគ្គលិកកុងស៊ុល ត្រូវកំណត់ដោយរដ្ឋជាក់កុងស៊ុល និង ត្រូវមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ ។

៣. រាល់ការផ្លាស់ប្តូរដោយថាហេតុណាមួយ នៃទីតាំងលំដាប់ថ្នាក់និងមណ្ឌលកុងស៊ុលរបស់ប៉ុស្តិ៍កុងស៊ុល អាចធ្វើបានដោយរដ្ឋជាក់កុងស៊ុល លុះត្រាតែមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះតែប៉ុណ្ណោះ ។

៤. ត្រូវឱ្យមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះផងដែរ ក្នុងករណីស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល មានបំណងបើកស្ថានអនុកុងស៊ុល ឬ ក៏ទីភ្នាក់ងារកុងស៊ុល នៅកន្លែងមួយផ្សេងទៀតពីកន្លែងដែលស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលតាំងនៅ ។

៥. ត្រូវឱ្យមានការយល់ព្រមជាក់លាក់ជាមុនពីរដ្ឋម្ចាស់ផ្ទះផងដែរ ចំពោះការបើកការិយាល័យណាមួយ ដែលជាផ្នែកមួយនៃប៉ុស្តិ៍កុងស៊ុលដែលមានរួចហើយ នៅកន្លែងមួយផ្សេងទៀតពីទីតាំងរបស់ប៉ុស្តិ៍កុងស៊ុល ។